ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិធាន និងយន្តការដោះស្រាយបញ្ហាទំនាស់ផលប្រយោជន៍

- យោងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ (មាត្រា ២៧)
- យោងប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៤ (ប្រការ៧ និង ប្រការ១៥ )
- យោងគោលការណ៍ណែនាំផ្នែកវិជ្ជាជីវៈរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញសទ្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧ (ទំព័រទី៦)

## សាវតា

- ដោយយល់ឃើញថា ជីវិតក្នុងសង្គម តម្រូវឱ្យមានទំនាក់ទំនង ហើយទំនាក់ទំនងនេះ កាន់តែកើនឡើង នៅពេលដែលការងារមានកាន់តែច្រើនឡើងថែមទៀត។ ហេតុនេះ នៅពេលទំនាក់ទំនងការងារ កាន់តែច្រើន ទំនាស់ផលប្រយោជន៍ (ទ.ផ) ក៏អាចកើតមានឡើង ដោយជៀសមិនផុតដែរ ជាពិសេស ទ.ផ នៅក្នុងការបំពេញវិជ្ជាជីវៈ។ ជាក់ស្ដែង ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺជាស្ថាប័នដែលត្រូវបានបង្កើតឡើង ដោយច្បាប់ស្ដីពីការងារ ហើយសមាជិករបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនីមួយៗ មានភារៈកិច្ច និង តួនាទី ដោះស្រាយវិវាទការងារដោយឯករាជ្យ មិនលំអៀង និងប្រកបដោយលក្ខណៈវិជ្ជាជីវៈ។ ទ.ផ អាចកើតមានឡើងពាក់ព័ន្ធនឹងសកម្មភាពការងារឯកជន ទំនាក់ទំនងបុគ្គល ទំនាក់ទំនងក្នុងសហគមន៍ ឬ ក្នុងកន្លែងធ្វើការ និង ឬ ពាក់ព័ន្ធនឹងផលប្រយោជន៍គ្រួសារ ជាដើម។ ដោយសារ ទ.ផ អាចនាំឱ្យមានការលំអៀងក្នុងការបំពេញភារៈកិច្ច និងតួនាទីរបស់អាជ្ញាកណ្ដាល ដូចនេះ ជាការចាំបាច់ដែលក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវមានវិធាន និងយន្តការដោះស្រាយបញ្ហា ទ.ផ ទាំងនោះ។



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◆ Website: www.arbitrationcouncil.org

- ថ្វីត្បិត ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអនុម័តនូវគោលការណ៍ណែនាំផ្នែកវិជ្ជាជីវៈរបស់ខ្លួន ក្នុងឆ្នាំ ២០០៨ រួចហើយក៏ដោយ ប៉ុន្តែ មិនទាន់មានវិធាន និងយន្តការសម្រាប់ដោះស្រាយ ទ.ផ នៅឡើយ។ ដូច្នេះ នៅខែកញ្ញា ឆ្នាំ២០១០ អាជ្ញាកណ្តាលមួយចំនួន ក៏បានផ្តួចផ្តើមតាក់តែងឡើងនូវវិធាន និងយន្តការសម្រាប់ដោះស្រាយបញ្ហា ទ.ផ ដូចខាងក្រោមនេះ និងបានដាក់ជូនសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្រប់រូប មានឱកាសផ្តល់យោបល់ ម្តងហើយម្តងទៀត ដែលមានខ្លឹមសារដូចខាងក្រោម :

ប្រការ ១ : វិធាន និងយន្តការដោះស្រាយ ទ.ផ មានគោលបំណងផ្តល់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល នូវមធ្យោបាយសមស្រប សម្រាប់គ្រប់គ្រង និងដោះស្រាយ ទ.ផ ដែលអាចកើតមាននាពេលបច្ចុប្បន្ន និងអនាគត។ តាមរយៈ វិធាន និងយន្តការដោះស្រាយ ទ.ផ នេះ អាជ្ញាកណ្តាលម្នាក់ៗអាចរក្សាបាននូវសុចរិតភាព និង ប្រសិទ្ធភាពរបស់ខ្លួន ក្នុងការងារដោះស្រាយវិវាទការងារ រវាងនិយោជក និងកម្មករនិយោជិត ប្រកបដោយ ឯករាជ្យភាព ភាពឥតលំអៀង និងភាពជឿទុកចិត្តបាន ដើម្បីជាផលប្រយោជន៍របស់គូភាគី តាមរយៈការបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ក៏ដូចជា ចូលរួមចំណែកដល់ការលូតលាស់ផ្នែកសេដ្ឋកិច្ចជាតិទាំងមូលប្រកបដោយសមធម៌។

ប្រការ ២ : ត្រូវចាត់ទុកថា ជាករណីមានទំនាស់ផលប្រយោជន៍ នៅពេលដែលផលប្រយោជន៍ឯកជន ឬសមូហភាពរបស់អាជ្ញាកណ្តាលម្នាក់ដែលត្រូវបានជ្រើសរើសជាសមាជិកក្រុមអាជ្ញាកណ្តាលសម្រាប់សំណុំរឿងណាមួយ មានឥទ្ធិពលអវិជ្ជមាន ឬ ត្រូវបានគេមើលឃើញដោយសមហេតុផលថា មានឥទ្ធិពលអវិជ្ជមានទៅលើការបំពេញតួនាទី និងភារកិច្ច ក្នុងនាមជាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងនោះ។

**ប្រការ ៣ : សកម្មភាព ឬទំនាក់ទំនងដែលចាត់ទុកថាមានទំនាស់ផលប្រយោជន៍**

សកម្មភាព ឬទំនាក់ទំនងដែលចាត់ទុកថាមានទំនាស់ផលប្រយោជន៍ក្នុងការបំពេញតួនាទី និងភារៈកិច្ច ជាអាជ្ញាកណ្តាល ហើយអាជ្ញាកណ្តាលពាក់ព័ន្ធរូបនោះ ត្រូវពិចារណាបដិសេធខ្លួនឯងចេញពីក្រុមអាជ្ញាកណ្តាលនៃសំណុំរឿងនោះ មានជាអាទិ៍ ៖

**៣.១ ទំនាក់ទំនងការងារ ជាមួយភាគីវិវាទ**[1]

---

១ ប្រការ ១៥ នៃប្រកាស០៩៩ បានចែងថា "សមាជិកម្នាក់ៗនៃក្រុមអាជ្ញាកណ្តាល ត្រូវបដិសេធខ្លួនឯងពីក្រុមអាជ្ញាកណ្តាលដែលខ្លួនត្រូវបានគេជ្រើសរើស ប្រសិនបើកាលៈទេសៈដែលកើតមានឡើង ចោទជាមន្ទិលសង្ស័យសមស្របអំពីភាពមិនលំអៀង ឬ ឯករាជ្យភាពរបស់ខ្លួន រួមមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈ បុគ្គល ឬអាជីពជាមួយសមាជិកដទៃទៀត នៃក្រុមអាជ្ញាកណ្តាល ឬជាមួយភាគីណាមួយ ឬដោយមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍អាជីពផ្ទាល់ពីលទ្ធផលនៃរឿងក្តីនោះ។"

- អាជ្ញាកណ្តាល ជានិយោជករបស់ភាគីនៃវិវាទ ឬ ភាគីនៃវិវាទ ជានិយោជករបស់អាជ្ញាកណ្តាល។

**៣.២ ទំនាក់ទំនងវិជ្ជាជីវៈ ឬ សេវាកម្ម ជាមួយភាគីវិវាទ[2]**

- អាជ្ញាកណ្តាល ជាសមាជិកការិយាល័យមេធាវី ឬ ការិយាល័យដទៃទៀត ដែលផ្តល់សេវាពិគ្រោះយោបល់ ឬ សេវាផ្សេងៗទៀត ដល់ភាគីណាមួយនៃវិវាទ។
- អាជ្ញាកណ្តាលជា មេធាវី ឬ អ្នកពិគ្រោះយោបល់ ដែលផ្តល់សេវាផ្ទាល់ដល់ភាគីវិវាទ។
- អាជ្ញាកណ្តាល ធ្លាប់ជាមេធាវី ឬ អ្នកពិគ្រោះយោបល់ ដែលបានផ្តល់សេវាផ្ទាល់ដល់ភាគីវិវាទក្នុងរយៈពេល ១២ខែមុន គិតមកដល់ថ្ងៃអាជ្ញាកណ្តាលទទួលសំណុំរឿង[3] ដែលសេវានោះមាន ដូចជាការពិនិត្យ និងផ្តល់យោបល់លើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ការរៀបចំកិច្ចសន្យាការងារ ការពិនិត្យ ឬផ្តល់យោបល់ផ្នែកគណនេយ្យ ឬ ផ្នែកសុខភាព ការបណ្តុះបណ្តាលអប់រំអំពីច្បាប់ការងារជាដើម។

**៣.៣ ទំនាក់ទំនងបុគ្គលជាមួយភាគីវិវាទ[4]**

- សហព័ទ្ធ ឬ អតីតសហព័ទ្ធរបស់អាជ្ញាកណ្តាល ជាអ្នកផ្តល់ការប្រឹក្សាយោបល់ ទៅភាគីក្នុងដំណើការនៃសំណុំរឿងវិវាទ ឬ ជាភាគីផ្ទាល់នៃសំណុំរឿងវិវាទ។
- ញាតិលោហិត ក្នុងថ្នាក់ទី៣ ឬ ញាតិពន្ធ ឬអតីតញាតិពន្ធ ក្នុងថ្នាក់ទី២ របស់អាជ្ញាកណ្តាលជាភាគីនៅក្នុងសំណុំរឿងវិវាទ។
- អាជ្ញាកណ្តាល ជាអ្នកអាណាព្យាបាលរបស់ភាគីវិវាទ។
- អាជ្ញាកណ្តាល ធ្លាប់មានវិវាទ (ក្នុងរយៈពេល ១២ខែមុន គិតមកដល់ថ្ងៃអាជ្ញាកណ្តាលទទួលសំណុំរឿង) ឬ កំពុងមានវិវាទ តតាំងគ្នានៅតុលាការ ជាមួយភាគីវិវាទ ក្នុងនាមខ្លួនឯងផ្ទាល់ ឬ ក្នុងនាមជាអ្នកតំណាងការពារផលប្រយោជន៍របស់ភាគីវិវាទ។

**៣.៤ ទំនាក់ទំនងហិរញ្ញវត្ថុ**

---

[2] មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុច ឃ ការដកហូតចៅក្រមចេញពីសមត្ថកិច្ចជំនុំជម្រះ: ចៅក្រមត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួន កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី។

[3] ប្រការ៧ នៃប្រកាស០៩៩ បានចែងថា “បុគ្គលដែលមិនអាចត្រូវបានតែងតាំងជាសមាជិក្រុមប្រឹក្សាអាជ្ញាកណ្តាលមានដូចតទៅ : ... ខ. ម្ចាស់ ឬអ្នកគ្រប់គ្រងនៃសហគ្រាសណាមួយដែលជាសមាជិកនៃអង្គការនិយោជក ឬអ្នកដែលកាន់តំណែងផ្លូវការរបស់អង្គការនិយោជកណាមួយ ឬ អ្នកដែលធ្លាប់កាន់កាប់តំណែងទាំងនេះក្នុងរយៈពេល ១២ ខែមុន។”

[4] មាត្រា២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុច ក ការដកហូតចៅក្រមចេញពីសមត្ថកិច្ចជំនុំជម្រះ: ចៅក្រមត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួន កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី។

- អាជ្ញាកណ្ដាល ធ្លាប់មានភាគហ៊ុន (ក្នុងរយៈពេល ១២ខែមុន គិតមកដល់ថ្ងៃអាជ្ញាកណ្ដាលទទួលសំណុំរឿង) ឬ កំពុងមានភាគហ៊ុនលើអចលនទ្រព្យ ឬ ក្នុងក្រុមហ៊ុន ប្រភេទណាក៏ដោយ ជាមួយភាគីនៃវិវាទ ។
- អាជ្ញាកណ្ដាល ធ្លាប់ជាប់បំណុល (ក្នុងរយៈពេល ១២ខែមុន គិតមកដល់ថ្ងៃអាជ្ញាកណ្ដាលទទួលសំណុំរឿង) ឬ កំពុងជាប់បំណុលជាមួយភាគីវិវាទ ។

**៣.៥ ទំនាក់ទំនងផ្សេងទៀត**

ក្រៅពីទំនាក់ទំនងដូចមានចែងនៅក្នុងចំណុច ៣.១ ដល់ ៣.៤ ខាងលើ ភាគីវិវាទអាចលើកឡើងអំពីទំនាក់ទំនងផ្សេងទៀត ប្រសិនបើមានហេតុផលសមរម្យ ដើម្បីអាចបញ្ជាក់អំពី ទ.ផ ហើយអាជ្ញាកណ្ដាលពាក់ព័ន្ធរូបនោះ ត្រូវពិចារណាបដិសេធខ្លួនឯងចេញពីក្រុមអាជ្ញាកណ្ដាលនៃសំណុំរឿងនោះ ប្រសិនបើការលើកឡើងនោះមានហេតុផល និងភស្តុតាង គ្រប់គ្រាន់ និងច្បាស់លាស់ ។

**ប្រការ ៤: វិធានការគ្រប់គ្រងករណីមានបញ្ហាទំនាស់ផលប្រយោជន៍**

**៤.១ មុនសវនាការ**

- លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវបញ្ជាក់ពីឈ្មោះរបស់ក្រុមអាជ្ញាកណ្ដាលសម្រាប់សំណុំរឿងនោះ នៅក្នុងលិខិតអញ្ជើញភាគីចូលរួមសវនាការ ។
- បន្ទាប់ពីទទួលការជ្រើសរើស អាជ្ញាកណ្ដាល ត្រូវប្រកាសពីទំនាក់ទំនងផលប្រយោជន៍ជាមួយភាគីវិវាទណាមួយដែលខ្លួនដឹង ឬ សង្ស័យ ទៅសមាជិកផ្សេងទៀតនៃក្រុមអាជ្ញាកណ្ដាល ។
- អាជ្ញាកណ្ដាល ដែលមាន ឬ សង្ស័យថាមាន ទ.ផ ត្រូវពិចារណាបដិសេធខ្លួនឯងចេញពីក្រុមអាជ្ញាកណ្ដាល ។
- ប្រសិនបើអាជ្ញាកណ្ដាលដែលមាន ឬ សង្ស័យថាមាន ទ.ផ មិនបដិសេធខ្លួនឯងចេញពីក្រុមអាជ្ញាកណ្ដាលនោះទេ គណៈកម្មការគ្រប់គ្រង ទ.ផ នឹងធ្វើការជំរុញ និងលើកយោបល់ឱ្យអាជ្ញាកណ្ដាលដែលមាន ទ.ផ នោះ បដិសេធខ្លួនឯងចេញពីក្រុមអាជ្ញាកណ្ដាល ។
- ប្រសិនបើអាជ្ញាកណ្ដាលដែលមាន ឬ សង្ស័យថាមាន ទ.ផ នោះ នៅតែបន្តធ្វើជាសមាជិកក្រុមអាជ្ញាកណ្ដាលសម្រាប់សំណុំរឿងនោះ អាជ្ញាកណ្ដាលនោះត្រូវបង្ហាញ និង បំភ្លឺនូវយោបល់របស់ខ្លួនដែលយល់ថាគ្មាន ទ.ផ ឬ គ្មានឥទ្ធិពលអវិជ្ជមានលើការវិនិច្ឆ័យរបស់ខ្លួន ដល់គូភាគី នៅក្នុងពេលសវនាការ និងសួរបញ្ជាក់ទៅភាគីថា តើភាគីជំទាស់ទៅលើសមាសភាពខ្លួនជាអាជ្ញាកណ្ដាល ក្នុងសំណុំរឿងឬទេ ។

- ប្រសិនបើភាគី ជំទាស់លើសមាសភាពរបស់ខ្លួន អាជ្ញាកណ្តាលនោះ ត្រូវពិចារណាបដិសេធខ្លួនឯងចេញពីសមាជិកក្រុមអាជ្ញាកណ្តាល សម្រាប់សំណុំរឿងនោះ។

- ប្រសិនបើភាគី ជំទាស់លើសមាសភាពរបស់ខ្លួន ហើយអាជ្ញាកណ្តាលនោះសម្រេចថា មិនបដិសេធខ្លួនឯងចេញពីសមាជិកក្រុមអាជ្ញាកណ្តាល អាជ្ញាកណ្តាលនោះត្រូវបកស្រាយពីការមិនមាន ទ.ផ ឬ គ្មានឥទ្ធិពលអវិជ្ជមានលើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល សម្រាប់សំណុំរឿងនោះ ។

**៤.២ អំឡុងពេលសវនាការ**

**៤.២.១ អាជ្ញាកណ្តាលបានដឹងអំពី ទ.ផ**

- អាជ្ញាកណ្តាលដែលបានដឹងថាខ្លួនមាន **ទ.ផ** ត្រូវប្រកាសពីករណីមាន **ទ.ផ** ដល់គូភាគីវិវាទក្នុងអំឡុងពេលសវនាការ និងត្រូវពិចារណាបដិសេធខ្លួនឯងចេញពីក្រុមអាជ្ញាកណ្តាល។

- ប្រសិនបើអាជ្ញាកណ្តាលដែលមាន **ទ.ផ** នោះ នៅតែបន្តជាសមាជិកក្រុមអាជ្ញាកណ្តាល អាជ្ញាកណ្តាលនោះ ត្រូវសួរបញ្ជាក់ទៅភាគីថា តើភាគីជំទាស់ទៅលើសមាសភាពខ្លួន ជាអាជ្ញាកណ្តាល ក្នុងសំណុំរឿងឬទេ។

- ប្រសិនបើភាគីជំទាស់លើសមាសភាពរបស់ខ្លួន អាជ្ញាកណ្តាលនោះត្រូវពិចារណាបដិសេធខ្លួនឯងចេញពីសមាជិកក្រុមអាជ្ញាកណ្តាល។

- ប្រសិនបើភាគីជំទាស់លើសមាសភាពរបស់ខ្លួន ហើយអាជ្ញាកណ្តាលនោះសម្រេចថា មិនបដិសេធខ្លួនឯងចេញពីសមាជិកក្រុមអាជ្ញាកណ្តាល អាជ្ញាកណ្តាលនោះត្រូវបកស្រាយពីការមិនមាន **ទ.ផ** ឬ គ្មានឥទ្ធិពលអវិជ្ជមានលើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

- រាល់ការបកស្រាយពីការមិនមាន **ទ.ផ** ឬ គ្មានឥទ្ធិពលអវិជ្ជមានលើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីបង្គាប់មួយ អាចត្រូវបានធ្វើឡើងក្នុងនាមអាជ្ញាកណ្តាលដែលត្រូវបានភាគីជំទាស់ ឬ ក្នុងនាមក្រុមអាជ្ញាកណ្តាលនៃសំណុំរឿងទាំងមូល អាស្រ័យលើកាលៈទេសៈជាក់ស្តែងទាក់ទងនឹងការសម្រេចមិនបដិសេធខ្លួនឯង ឬ ការបកស្រាយនោះត្រូវបញ្ជាក់ថា មាន ឬគ្មានការគាំទ្រដោយសមាជិកផ្សេងទៀតនៃក្រុមអាជ្ញាកណ្តាលសម្រាប់សំណុំរឿងនោះ។

## ប្រការ៥: យន្តការដោះស្រាយ

**៥.១ សមាសភាពគណៈកម្មការគ្រប់គ្រងទំនាស់ផលប្រយោជន៍**

- សមាជិកនៃក្រុមអាជ្ញាកណ្តាល

- ប្រធានផ្នែកសេវាច្បាប់នៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ប្រធានលេខាធិការក្រុមប្រឹក្សាអាជ្ញាកណ្តាល

**៥.២ តួនាទីរបស់គណៈកម្មការគ្រប់គ្រងទំនាស់ផលប្រយោជន៍**

- ឃ្លាំមើល និងទទួលព័ត៌មានអំពីករណីសង្ស័យ ឬការលើកឡើងនូវ **ទ.ផ**
- ស្រាវជ្រាវ និងផ្តល់ព័ត៌មានអំពីករណីសង្ស័យ ឬការលើកឡើងនូវ **ទ.ផ**
- លើកយោបល់ជូនក្រុមអាជ្ញាកណ្តាល ដើម្បីឱ្យអាជ្ញាកណ្តាលដែលមាន ឬសង្ស័យថាមាន **ទ.ផ** ពិចារណាបដិសេធខ្លួនឯងចេញពីសំណុំរឿង ។

**ប្រការ ៦:** វិធាន និងយន្តការដោះស្រាយទំនាស់ផលប្រយោជន៍នេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី...29... ខែ ...មិថុនា... ឆ្នាំ២០ ...12... តទៅ ។

**អាជ្ញាកណ្តាលមកពីបញ្ជីក្រសួង**

១. សុខ ម៉ាធឿង ហត្ថលេខា៖ ________________

២. គង់ ផល្លៈ ហត្ថលេខា៖ ________________

៣. ប៉ែន ប៊ុនឈា ហត្ថលេខា៖ ________________

៤. អាំង អេងថុង ហត្ថលេខា៖ ________________

៥. ញាន សុមុន្និទ្ធ ហត្ថលេខា៖ ________________

៦. ម៉ែន និម្មិត ហត្ថលេខា៖ ×____________________

៧. កុយ នាម ហត្ថលេខា៖ ____________________

៨. តាំង ទ្រី ហត្ថលេខា៖ ×____________________

៩. រុន សារ៉ាយ ហត្ថលេខា៖ ____________________

១០. គីម-យ៉ាត ដារ៉ារិទ្ធ ហត្ថលេខា៖ ____________________

**អាជ្ញាកណ្តាលមកពីបញ្ញើនិយោជក**

១. ម៉ារ សំបូរណា ហត្ថលេខា៖ ____________________

២. អ៊ុក វី ហត្ថលេខា៖ ____________________

៣. យូ សួនទី ហត្ថលេខា៖ ____________________

៤. ហែម ហួណារិទ្ធ ហត្ថលេខា៖ ____________________

៥. កៅ ថាច		ហត្ថលេខា៖ ______________________

៦. លី តៃសេង		ហត្ថលេខា៖ ______________________

៧. គល់ វឌ្ឍនា		ហត្ថលេខា៖ ______________________

៨. អ៊ឹង សុទ្ធី		ហត្ថលេខា៖ ______________________

៩. សេង វ៉ូចហ៊ុន		ហត្ថលេខា៖ ______________________

១០. ឈីវ ភិរម្យ		ហត្ថលេខា៖ ______________________

**អាជ្ញាកណ្តាលមកពីបុគ្គលិកនិយោជិត**

១. ទូន ស៊ីផាន់		ហត្ថលេខា៖ ______________________

២. អន ណន		ហត្ថលេខា៖ ______________________

៣. វង្ស វណ្ណា ហត្ថលេខា៖ ____________________

៤. សុង វណ្ណស៊ីន ហត្ថលេខា៖ ____________________

៥. វ៉ែន ពៅ ហត្ថលេខា៖ ____________________

៦. ស៊ីន គីមស៊ាន ហត្ថលេខា៖ ____________________

៧. ហួន ជុនឌី ហត្ថលេខា៖ ____________________

៨. សួង សុផល ហត្ថលេខា៖ ____________________

៩. លីវ សុវណ្ណា ហត្ថលេខា៖ ____________________

១០. អាន វីរៈ ហត្ថលេខា៖ ____________________